# ការថ្វាយដំណឹង

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ចំពោះព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម-សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា អំពីក្រសួងធម្មការនិងកិច្ចការសាសនាបាននិងកំពុងធ្វើសកម្មភាពបំផ្លាញព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋកម្ពុជា

web site: hoksavann.org

សូមថ្វាយដំណឹងអំពីសកម្មភាពខ្លះរបស់ក្រសួងធម្មការនិងកិច្ចការសាសនាមានលក្ខណ:បំផ្លាញព្រះពុទ្ធសាសនា ។

តាមដំណឹងថា នៅថ្ងៃទី១០មីនា២០០៦នេះ មន្ត្រីធម្មការនឹងទៅធ្វើរបាយការណ៍អំពីសកម្មភាពរបស់ក្រសួងធម្មការ ទូលថ្វាយព្រះអង្គ ។ ពេលនេះអាត្មាសូមទូលថ្វាយ អំពីក្រសួងធម្មការសម័យសង្គមរាស្ត្រនិយមនិងក្រសួងធម្មការសម័យនេះ ដោយសូមលើកយកមករៀបរាប់ជាពិសេស អំពីសកម្មភាពខុសប្រក្រតីរបស់ក្រសួងធម្មការសម័យនេះ ដែលមានសកម្មភាពខ្លះបំផ្លាញព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនាជាបាវចនាមួយរបស់ប្រទេសកម្ពុជា ក្នុងបណ្តាបាវចនាទាំងបីគឺជាតិ-សាសនា-ព្រះមហាក្សត្រ ដោយចាត់ទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដែលរដ្ឋត្រូវការពារនិងឧបត្ថម្ភឲ្យចំរើនរុងរឿង ហើយព្រះមហាក្សត្រខ្មែរតែងតែលើកដំកើងព្រះពុទ្ធសាសនា ជាពុទ្ធសាសនូបត្ថម្ភ តាំងពីព្រះមហាក្សត្រជំនាន់មុនៗមក រហូតមកដល់បច្ចុប្បន្ននេះ ។ ជាមួយគ្នានេះដែរ សូមកោតសរសើរចំពោះគណបក្សប្រជាជន ដែលធ្វើឲ្យព្រះពុទ្ធសាសនារស់ឡើងវិញ បន្ទាប់ពីត្រូវបានបំផ្លាញដោយរបបប៉ុល-ពត ។

មួយទៀតសូមសំដែងការត្រេកអរជាទីបំផុត ចំពោះការលើកដំកើងព្រះពុទ្ធសាសនាឲ្យរីកលូតលាស់ របស់ប្រមុខរាជរដ្ឋាភិបាលខ្មែរ ដែលបានអនុញ្ញាតច្បាប់ពីពុទ្ធិកមហាវិទ្យាល័យ ឲ្យទៅជាពុទ្ធិកសកលវិទ្យាល័យ, អនុញ្ញាតឲ្យបង្កើតមហាវិទ្យាល័

យគរុកោសល្យ និងអនុញ្ញាតឲ្យព្រះសង្ឃទៅអប់រំកុមារា-កុមារី យុវជន-យុវនារីជាសិស្សនិស្សិតនៅតាមសាលារៀននៃក្រសួងអប់រំ ។ សូមអរព្រះគុណចំពោះសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជគណៈមហានិកាយ និងកោតសរសើរចំពោះនាយកខុទ្ទកាល័យ ដែលជាសហការី បានធ្វើសំណើរពខខាងលើនេះ ដល់ប្រមុខរាជរដ្ឋាភិបាល ។ ប៉ុន្តែគួរឲ្យស្តាយអំពីរចនាសម្ព័ន្ធនិងសកម្មភាពខ្លះរបស់ក្រសួងធម្មការ និងកិច្ចការសាសនា មានភាពខុសប្រក្រតី ឆ្ពោះទៅរកការបំផ្លាញព្រះពុទ្ធសាសនា ដែលមានលក្ខណៈផ្ទុយអំពីប្រមុខដឹកនាំរាជរដ្ឋាភិបាលខ្មែរទៅវិញ ។ កាលពីសម័យសង្គមរាស្ត្រនិយម ក្រសួងធម្មការមានអនុរដ្ឋលេខាធិការ ក្រោយមកដំឡើងជារដ្ឋលេខាធិការ ជាតំណាងរាជរដ្ឋាភិបាលផ្នែកព្រះពុទ្ធសាសនា ទាក់ទងមកក្រសួងសង្ឃរាជ ។ ក្រសួងធម្មការទាំងមូលធ្វើការបំរើព្រះពុទ្ធសាសនា ហើយមន្ត្រីធម្មការជាអ្នកព្រះពុទ្ធសាសនា ចេះដឹងព្រះពុទ្ធសាសនា ពុំមានតំណាងសាសនាភាគតិច នៅក្នុងក្រសួងធម្មការនោះឡើយ គ្រប់កិច្ចការរបស់សាសនាភាគតិច មកទាក់នឹងក្រសួងធម្មការ ដែលជាតំណាងព្រះពុទ្ធសាសនានេះឯង ។ មកដល់បច្ចុប្បន្ន នេះពោលត្រឹមឆ្នាំ១៩៩៣ មកដល់ដើមឆ្នាំ២០០៦នេះ ពេលដែលមានការបង្រួបបង្រួមជាតិតាមផ្លូវនយោបាយមក អ្នកនយោបាយខ្មែរចែកកូតាគ្នា នៅពេលធ្វើរដ្ឋាភិបាលចំរុះ ពេលនោះរដ្ឋមន្ត្រីក្រសួងធម្មការបានមកគណបក្សហ៊្វុនស៊ិនប៉ិចរហូត៣អាណាត្តិ ។

គណបក្សហ៊្វុនស៊ិនប៉ិចមិនដាក់មន្ត្រីធម្មការ ជាអ្នកជំនាញការខាងព្រះពុទ្ធសាសនាទេ តែដាក់អ្នកជំនាញការខាងដុល្លារទៅវិញ បានសេចក្តីថាជនណាផ្តល់ប្រាក់ដុល្លារឲ្យច្រើនជាងគេ ជននោះត្រូវបានធ្វើជារដ្ឋមន្ត្រីក្រសួងធម្មការ គឺលក់កូតាថ្នាក់រដ្ឋមន្ត្រី ពុំដឹងជាមានតម្លៃប៉ុន្មានទេ នេះជាពត៌មានគេប្រាប់ពីភ្នំពេញ បើពុំពិតកុំឲ្យមានបាប ។ មកដល់អាណាត្តិទី៣ឆ្នាំ២០០៣នេះ រដ្ឋមន្ត្រីក្រសួងធម្មការគឺលោកយុន-ហាំង ជាអ្នកកាន់គ្រឹស្តសាសនា ហើយមានរដ្ឋលេខាធិការម្នាក់ ជាអ្នកកាន់សាសនាឥស្លាម ។ ឯអ្នកកាន់ព្រះពុទ្ធសាសនា ឲ្យកាន់តំណែងត្រឹមតែអនុរដ្ឋលេខាធិការ ។ ដោយសារឲ្យអ្នកកាន់គ្រឹស្តសាសនាមានតំណែងរហូតដល់ថ្នាក់រដ្ឋមន្ត្រីត្រួតត្រាលើអ្នកកាន់ព្រះពុទ្ធសាសនានេះហើយ បានជាកិច្ចការព្រះពុទ្ធសាសនាមានជំទាស់ជាមួយព្រះសង្ឃព្រះពុទ្ធសាសនា ជាពិសេសមានទំនាស់ជាមួយអគ្គាធិការនៃពុទ្ធិកសិក្សា សូមលើកយកឧទាហរណ៍ពីរមកបញ្ជាក់ទំនាស់នេះ គឺទី១- ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ ដែលក្រសួងការបរទេសបានខ្ចី ត្រូវគេបង្វិលប្រគេនអគ្គាធិការនៃពុទ្ធិកសិក្សាវិញ តែត្រូវលោកយុន-ហាំងជំទាស់ បំណាងយកពុទ្ធិកសកលវិទ្យាល័យនេះ ជួលឲ្យរដ្ឋសភាខ្មែរ ប៉ុន្តែបានត្រូវព្រះសង្ឃប្រឆាំងយ៉ាងខ្លាំងក្លា ក៏ទទួលបរាជ័យទៅ ។ ទី២- លោកយួន-ហាំងទៅបញ្ចុះបញ្ចូលក្រសួងពត៌មាន ធ្វើសារាចររួមមួយ ដាក់ច្បាប់រឹតបន្តឹងព្រះសង្ឃទេសនា ដោយចែងថា ព្រះសង្ឃមុននឹងទេស

នាតាមវិទ្យុនិងទូរទស្សន៍ទូទាំងប្រទេសកម្ពុជាទាំងមូល ត្រូវតែសុំច្បាប់និងមានការត្រួតពិនិត្យពីក្រសួងធម្មការ ។ ទំរើបង្អាក់ដំណើរការលួតលាស់របស់ព្រះពុទ្ធសាសនា ដោយចេញច្បាប់ខុសទម្លាប់ប្រកបដោយចេតនាបែបនេះ បានត្រូវព្រះសង្ឃព្រះពុទ្ធសាសនាប្រឆាំងយ៉ាងខ្លាំងក្លា សារាចរនោះក៏មិនអាចមានសុពលភាពតទៅមុខទៀត ។

<u>សាសនាបរទេសដែលបានកើតឡើងនៅកម្ពុជា</u>
<u>ដោយសារព្រឹត្តិការណ៍កើតឡើងមិនប្រក្រតី</u>

១- រចនាសម្ព័ន្ធក្រសួងធម្មការ បានតែងតាំងមនុស្សជាអ្នកកាន់គ្រឹស្តសាសនា និងអ៊ិស្លាមសាសនា ដល់ថ្នាក់រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការ ។

២- ប្រជាពលរដ្ឋខ្មែរកំពុងស្ថិតនៅក្នុងភាពក្រីក្រ និងបញ្ញាស្មារតីមានភាពទន់ខ្សោយ ។

៣- រដ្ឋពុំមានច្បាប់គ្រប់គ្រាន់ទប់ទល់សាសនាបរទេស ដែលជ្រៀតចូលមកកម្ពុជាខុសប្រក្រតី ។

៤- មន្ត្រីធម្មការខ្លះប្រព្រឹត្តអំពើពុករលួយ ដោយបើកឲ្យគេសង់សាលា សង់ព្រះវិហារតាមអំពើចិត្ត ដោយសារដុល្លារ ។

៥- សាសនាបរទេសជាពិសេសគ្រឹស្តសាសនា យកអំណោយមនុស្សធម៌និងបង្រៀនភាសាអង់គ្លេស ជារនាំងបាំងមុខ ឬជានុយដើម្បីទាក់ទាញ ជនជាតិខ្មែរជាពិសេសយុវជនក្មេងៗ ឲ្យលះបង់ព្រះពុទ្ធសាសនា ចូលកាន់គ្រឹស្តសាសនាវិញ ។

<u>ដោយសារព្រឹត្តិការណ៍ខុសប្រក្រតីនេះហើយ ដែលធ្វើឲ្យ</u>
<u>ការិយាល័យ សាលា វិហារ នៃសាសនាដទៃកើតឡើងព្រោង</u>
<u>ព្រាតនៅកម្ពុជា សូមលើកយកតែសាសនាពីរ តាមស្ថិតិធម្មការ ។</u>

<u>សាសនាឥស្លាម</u> ៖

សម័យសង្គមរាស្ត្រនិយម ៖ ព្រះវិហារនិងសាលា មានចំនួនតិចណាស់ ។

សម័យបច្ចុប្បន្ននេះ ៖ បរិស័ទឥស្លាមមានចំនួន ២៩៥,៨៤៦នាក់ ព្រះវិហារមាន ២,២០៧ សាលាមាន ១២៩ និងសារាវ មាន ២៧០ ។

<u>គ្រឹស្តសាសនា</u> ៖

សម័យសង្គមរាស្ត្រនិយម ៖ ចំនួនមនុស្សអ្នកកាន់សាសនានេះ មានចំនួនតិចណាស់ ទាំងព្រះវិហារក៏មានចំនួនតិចដែរ ។

សម័យបច្ចុប្បន្ននេះ ៖ គ្រឹស្តបរិស័ទមានចំនួន ៥០,១១៩នាក់ ទីស្នាក់ការមានចំនួន៧៣០កន្លែង ព្រះវិហារមានចំនួន១៧០ និងសាលាមានចំនួន១១០ ។

តាមស្ថិតិនេះយើងឃើញថា អ្នកកាន់សាសនាឥស្លាម មានតែជាង២សែននាក់ ប៉ុន្តែចំនួនព្រះវិហារនិងសាលា មានជិត៣ពាន់ ជិតស្មើនឹងវត្តព្រះពុទ្ធសាសនា ដែលមានជាង៤ពាន់វត្ត ក្នុងចំណោមពុទ្ធបរិស័ទមានជាង១២លាននាក់ ។

គ្រីស្តសាសនាមានអ្នកកាន់តែ៥ម៉ឺននាក់ ប៉ុន្តែមានទីស្នាក់ការ ព្រះវិហារ និងសាលារហូតដល់ជាង១ពាន់ ។ គ្រាន់តែនៅទីក្រុងភ្នំពេញ មានទីស្នាក់ការសាសនាគ្រីស្តរហូតដល់៣០០កន្លែង ច្រើនជាងវត្តព្រះពុទ្ធសាសនា មានតែ៨៥វត្ត ។

នៅប្រទេសវៀតណាម មានអ្នកកាន់គ្រីស្តសាសនា៨លាននាក់ ប៉ុន្តែវិហារគ្រីស្ត គេអនុញ្ញាតឲ្យសង់តែចំនួន២៦ប៉ុណ្ណោះ ។

តើហេតុអ្វីបានជាមន្ត្រីធម្មការបើកឲ្យសាសនាទាំងពីរនេះ សង់សាលា, សង់ព្រះវិហារច្រើនម្ល៉េះ ? ដូចគ្រីស្តសាសនាគេសង់សង់ទីស្នាក់ការច្រើន ទុកជាផ្លាក់សំរាប់អូសទាញពុទ្ធបរិស័ទខ្មែរ ឲ្យចូលកាន់សាសនាគេ ។

## ច្បាប់បង្កើតវត្តខ្មែរក្នុងប្រទេសប្រជាធិបតេយ្យ

១- គោលបំណង ៖ ខ្មែរបង្កើតវត្តនេះដើម្បីរក្សាព្រះពុទ្ធសាសនារបស់ខ្លួន ។

២- ចំនួនមនុស្សប៉ុន្មាននាក់ដែលគេអាចអនុញ្ញាតឲ្យបង្កើតវត្ត ។

៣- គ្មានបំណងទាក់ទាញសាសនាដទៃ ឲ្យចូលកាន់ពុទ្ធសាសនាឡើយ ។

៤- ទីកន្លែងសាធារណៈ ដូចជាកន្លែងលក់ដូរ, កន្លែងរោងចក្រស្រាលៗ ពុំមានជាទីលំនៅ ដែលគេត្រូវការស្ងប់ស្ងាត់ដេកពួនដើម្បីទៅធ្វើការ ។

៥- មិនមានការប្រឆាំងនឹងអ្នកជិតខាង គឺមានការយល់ព្រមពីអ្នកជិតខាងផង។

នេះជាលក្ខខណ្ឌដែលអាចបង្កើតវត្តបាន តើមន្ត្រីធម្មការមានឲ្យសាសនាដទៃបំពេញលក្ខខណ្ឌនេះ ឲ្យមានគ្រប់គ្រាន់ឬទេ មុននឹងឲ្យបង្កើតវត្តឬព្រះវិហារ ។ មួយទៀតអ្នកដែលមានសិទ្ធិសុំបង្កើតវត្តនេះ បានតែពលរដ្ឋដែលមានសញ្ជាតិក្នុងប្រទេសនោះផ្ទាល់តែម្តង បរទេសដែលពុំមានសញ្ជាតិគេ ពុំមានសិទ្ធិសុំបង្កើតវត្តបានឡើយ ។ នៅប្រទេសដែលមានសេរីភាពកំពូល គ្មានឃើញគេអនុញ្ញាតឲ្យបរទេសតាំងការិយាល័យផ្សាយសាសនានៅប្រទេសគេឡើយ តើមន្ត្រីធម្មការហេតុអ្វីបានជាអនុញ្ញាត ឲ្យបរទេសតាំងការិយាល័យផ្សាយសាសនាគេ ដើម្បីអូសទាញអ្នកកាន់សាសនារបស់ខ្លួន ? អ្នកណាក៏ដឹងដែរថា សេរីភាពខាងជំនឿ ប៉ុន្តែសេរីភាពនៅក្នុងក្របខ័ណ្ឌច្បាប់របស់ប្រទេស ។

សេរីភាពខាងជំនឿ ប៉ុន្តែកុំឲ្យប៉ះឬរំលោភលើជំនឿអ្នកដទៃ ។ យ៉ាងណាមិញ ពុំមានជនជាតិខ្មែររត់ទៅរកសាសនាដទៃទេ គឺសាសនាដទៃមកបំបែកបំបាក់ខ្មែរឲ្យលះបង់សាសនារបស់ខ្លួន ទៅជឿសាសនាមួយទៀត ដោយល្បិចកិច្ចកលដោយរបៀបដាក់នុយ ទុកជាសម្លាប់ទឹកចិត្តមនោសញ្ចេតនាជំនឿរបស់គេ រហូតដល់កុមារាកុមារី ដែលជាវ័យពុំទាន់ចេះពិចារណា ក៏ពួកសាសនាគ្រីស្តទៅល្បួងលោមដែរ ដោយឲ្យចំណីអាហារ ឬជូនដើរលេង ដើម្បីបញ្ឆោតឲ្យជឿគ្រីស្តសាសនា នេះជា

ការរំលោភសិទ្ធិមនុស្សយ៉ាងជាក់ស្តែង ។ មិនត្រឹមតែនៅទីក្រុងទេ សាសនានេះបានតាំងការិយាល័យនៅពាសពេញប្រទេសកម្ពុជាទាំងមូល ជាពិសេសនៅខេត្តរតនគិរី មណ្ឌលគិរី ដែលមានជនជាតិភាគតិចនៅច្រើន ដែលនៅសម័យសង្គមរាស្ត្រនិយម ទាំងពុទ្ធសាសនិកជន ទាំងអាជ្ញាធរខេត្ត ពុំហ៊ានពន្យល់ណែនាំឲ្យចូលកាន់ព្រះពុទ្ធសាសនាឡើយ ដោយទុកសិទ្ធិឲ្យបងប្អូនភាគតិចទាំងនោះ រក្សាទុកនូវជំនឿរបស់ខ្លួន ឥឡូវនេះសាសនាគ្រឹស្ត ដែលជាជនបរទេសលូកដៃរំលងក្បាលអាជ្ញាធរខ្មែរ ទៅបញ្ចុះបញ្ចូលអូសទាញបងប្អូនភាគតិចទាំងនោះ ឲ្យលះបង់ជំនឿដើមរបស់ខ្លួន ឲ្យជឿសាសនារបស់គេ បែរជាអាជ្ញាធរខ្មែរធ្វើព្រងើយ ថែមទាំងធ្វើសហការទៀតផង ។ អាជ្ញាធរបើកទ្វារផ្ទះឲ្យគេចូល សម្លាប់សាសនា គឺព្រះពុទ្ធសាសនាដែលជាសាសនារបស់ជាតិខ្លួនទៅវិញ ។

ការបើកសិទ្ធិខាងជំនឿរបស់ប្រទេសកម្ពុជាសព្វថ្ងៃនេះ លើសពី Standard អន្តរជាតិ ក្លាយជាអនាធិបតេយ្យ គ្មានអនុវត្តច្បាប់ទម្លាប់ឲ្យបានត្រឹមត្រូវ បណ្តោយឲ្យបរទេសមើលងាយខ្មែរ ចង់សាសនាណាដើរឃោសនាកាន់ខិតប័ណ្ណផ្សាយនៅទីណាក៏បាន ។ នៅបរទេសធ្វើអ្វីមួយ ក៏ស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ ដូចការផ្សាយសាសនា បើគ្មានច្បាប់អនុញ្ញាតទេ ប៉ូលិសត្រូវចាប់ នេះចំពោះជនបរទេស ។

## ព្រះពុទ្ធសាសនាចុះខ្សោយ នាំឲ្យប្រទេសកម្ពុជា<br>មានវិបត្តិទៅអនាគត

១- ប្រទេសកម្ពុជាមានឯកភាពខាងសាសនាគឺ ព្រះពុទ្ធសាសនា សម័យសង្គមរាស្ត្រនិយម ប្រជាពលរដ្ឋខ្មែរគោរពបូជាព្រះពុទ្ធសាសនា មានរហូតដល់ទៅ៩៩ភាគរយ ។ ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅជាមូលដ្ឋាន គឺធម៌ អហិង្សា ការមិនបៀតបៀន ដែលពុំដែលមានបញ្ហាក្នុងសង្គមដោយបញ្ហាព្រះពុទ្ធសាសនា ដែលមិនដែលធ្វើឲ្យរដ្ឋពិបាកគ្រប់គ្រងឡើង ។ ឥឡូវនេះមានសាសនាដទៃមកប្រជែងមានការបារម្ភថ្ងៃក្រោយ អាចមានជំទាស់គ្នារវាងសាសនានិងសាសនា ដោយមានព្រឹត្តិការណ៍ពិភពលោក បានបញ្ជាក់រួចហើយ អំពីសាសនានៃប្រទេសខ្លះកំពុងបង្ហូរឈាមគ្នារហូតមកដល់សព្វថ្ងៃ ។ ចំពោះព្រះពុទ្ធសាសនា ក្នុងប្រវត្តិសាស្ត្រពិភពលោក ពុំដែលបង្ហូរឈាមគ្នាក្នុងបញ្ហាព្រះពុទ្ធសាសនាឡើយ មានតែគេបៀតបៀនខ្លួនវិញ ដូចមហាវិទ្យាល័យ នាលន្ទា នៃប្រទេសឥណ្ឌា ជាមហាវិទ្យាល័យព្រះពុទ្ធសាសនា បានត្រូវសាសនាមួយដុតកំទេចចោល ។ ក្រៅពីពុទ្ធសាសនា សាសនាខ្លះមាននយោបាយនៅពីក្រោយ ។

២- អាចមានជំទាស់គ្នាក្នុងគ្រួសារ អំពីបញ្ហាសាសនា ដោយសព្វថ្ងៃនេះ សាសនាគ្រឹស្តបានបញ្ចុះបញ្ចូលទាញយកយុវជនខ្មែរបានខ្លះ ដោយសារមន្ត្រីធម្មការចាត់ការមិនបានល្អ ។ យុវជនជាកូនដែលកាន់សាសនាដទៃ បង្កើតជម្លោះជាមួយឪពុកម្តាយខ្លួន ។ មានឧទាហរណ៍មួយនៅខេត្តកំពង់ធំ យុវជនខ្មែរមួយក្រុមដែលកាន់

គ្រីស្តសាសនា បានចូលទៅវាយព្រះពុទ្ធរូបនៅក្នុងព្រះវិហារនៃវត្តព្រះពុទ្ធសាសនា បាក់បែកខ្ទេចខ្ទីអស់ ។ មានវិហារគ្រីស្តសាសនាខ្លះសង់វត្តព្រះពុទ្ធសាសនា ថ្ងៃក្រោយអាចមានជំទាស់គ្នា ដោយមន្ត្រីធម្មការចេះតែអនុញ្ញាតច្បាប់ ពុំបានសួរយោបល់អ្នកកាន់ព្រះពុទ្ធសាសនា និងពុំបានគិតឲ្យវែងឆ្ងាយ ។

៣- ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា នឹងត្រូវវិនាសជាលើកទី២ (បន្ទាប់ពីវិនាសលើកទី១សម័យខ្មែរក្រហម) ដោយសារស្នាដៃរបស់ក្រសួងធម្មការ និងកិច្ចការសាសនាសព្វថ្ងៃនេះ ហើយការវិនាសពេលនេះ ពុំអាចរើខ្លួនរួចឡើយ ។ ការវិនាសព្រះពុទ្ធសាសនាសម័យប៉ុល-ពត អាចរើខ្លួនរួច បន្ទាប់ពីរបបប៉ុល-ពតត្រូវរលាយ ព្រោះខ្មែរទាំងអស់ជាអ្នកពុទ្ធសាសនា ។ ចំណែកការវិនាសពេលនេះ ពុំអាចរើខ្លួនរួចឡើយ ព្រោះមានបរទេសលូកដៃចូល ទាញយកបរិស័ទរបស់ខ្លួន ឲ្យទៅខាងគេ គឺគេសម្លាប់ចិត្តវិញ្ញាណខ្មែរ ហើយបញ្ចូលចិត្តវិញ្ញាណថ្មី ។

<u>អាជ្ញាធរខ្មែរគប្បីពង្រឹងពុទ្ធសាសនា</u>

១- គប្បីពង្រឹងព្រះពុទ្ធសាសនា ដោយពង្រីកពុទ្ធិកសិក្សា ឲ្យរីកឡើងថែមទៀត និងបញ្ជូនព្រះសង្ឃ សមណនិស្សិតឲ្យទៅសិក្សានៅប្រទេសដែលកាន់ពុទ្ធសាសនាដូចគ្នា ដើម្បីបង្កើនចំណេះដល់ព្រះសង្ឃ ឲ្យទៅជាអ្នកដឹកនាំព្រះពុទ្ធសាសនាដ៏ស្ទាត់ជំនាញ ។ ថែមពីលើនេះទៀត គប្បីណែនាំព្រះសង្ឃ ឲ្យគោរពតាមធម៌វិន័យឲ្យបានត្រឹមត្រូវ ។ និមន្តព្រះសង្ឃដែលមានសមត្ថភាព ទៅអប់រំកុមារា-កុមារី យុវជន-យុវនារី នៅតាមវត្តនានា នៅទីក្រុងនិងនៅតាមខេត្តនានា ព្រមទាំងអប់រំសិស្សនិស្សិត នៅតាមសាលារៀន គ្រប់ភូមិសិក្សា ដើម្បីលើកដំកើងសីលធម៌ ឲ្យខ្ពស់ឡើងវិញ ចំណែកចៅអធិការ អនុគណ មេគណ ត្រូវមានចំណេះដឹងនិងគុណធម៌ខ្ពង់ខ្ពស់ ធ្វើជាមេដឹកនាំអប់រំពុទ្ធបរិស័ទខ្មែរ តាមភូមិស្រុក ខេត្ត ក្រុង ឲ្យយល់កាន់តែច្បាស់ឡើងថែមទៀត អំពីតម្លៃនិងខ្លឹមសាររបស់ព្រះពុទ្ធសាសនា ក្នុងនាទីជួយសង្គមខ្មែរ ដោយពុទ្ធចក្រ ជួយជំរុញផ្លូវអាណាចក្រ ឲ្យបានលូតលាស់ខាងគុណធម៌ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

២- ត្រូវរៀបចំរចនាសម្ព័ន្ធក្រសួងធម្មការឡើងវិញ ឲ្យដូចសម័យសង្គមរាស្ត្រនិយម ដែលដាក់មន្ត្រីធម្មការ ជាអ្នកកាន់ព្រះពុទ្ធសាសនា ឯសាសនាភាគតិចដទៃទៀត មិនត្រូវមានតំណាងនៅក្នុងក្រសួងនេះទេ ។

៣- ត្រូវពិនិត្យសើរើសាលា វិហារ ទីស្នាក់ការនៃសាសនាទាំងនោះឡើងវិញ ដែលបានអនុញ្ញាតច្បាប់មិនប្រក្រតី ។ បើពិនិត្យទៅឃើញថា ជាការអនុញ្ញាតច្បាប់មិនប្រក្រតី ត្រូវដកការអនុញ្ញាតនោះចេញវិញ ។

៤- ត្រូវធ្វើច្បាប់គ្រប់គ្រងពាហិរសាសនា ។

៥- ត្រូវដាក់ទណ្ឌកម្មដល់មន្ត្រីធម្មការ តាមក្រុងនិងខេត្ត ដែលបានប្រព្រឹត្តខុស ។

៦- ត្រូវពិនិត្យតាមដានអង្គការមនុស្សធម៌ ដែលប្រព្រឹត្តខុសមុខនាទីខ្លួន អំពីការយកអង្គការមនុស្សធម៌បាំងមុខ ដើម្បីផ្សាយសាសនាខ្លួន បង្ខំខ្មែរឲ្យជឿ ។

រាជរដ្ឋាភិបាលខ្មែរប្រហែលជាពុំបានដឹងពិស្តាររឿងទាំងអស់នេះទេ, ទទួលខុសត្រូវនៅលើក្រសួងធម្មការ ហើយគណបក្សហ៊្វុនស៊ិនប៉ិចទទួលខុសត្រូវច្រើនជាងគេ ព្រោះជាកូតារបស់ខ្លួន ។ គួរឲ្យឆ្ងល់តំណាងរាស្ត្ររបស់គណបក្សហ៊្វុនស៊ិនប៉ិច ចេះតែធ្លាក់ចុះ ប្រហែលពុទ្ធបរិស័ទខ្មែរមិនពេញចិត្ត ដោយគណបក្សហ៊្វុនស៊ិនប៉ិចចេះតែលើកដំកើងសាសនាដទៃ រហូតតែងតាំងសាសនាដទៃ ឲ្យធ្វើជារដ្ឋមន្ត្រីថែមទៀត ។

សូមថ្វាយដំណឹងព្រះករុណាសម្តេចប៉ុណ្ណោះ ដើម្បីបានជាពត៌មានសំរាប់មានបន្ទូលទៅមន្ត្រីធម្មការ នៅថ្ងៃ១០ មីនា ២០០៦នេះ ហើយសូមព្រះអង្គមេត្តាធ្វើអន្តរាគមន៍ ទៅគណបក្សហ៊្វុនស៊ិនប៉ិច និងរាជរដ្ឋាភិបាល អំពីបញ្ហានេះតាមការគួរ ។

វត្តខ្មែរកាណាដា, ថ្ងៃទី៦ មីនា ២០០៦
ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ

❑ ❑

❑